https://www.inclusivedevelopment.net/court-decision-p…an-rights-abuses/

សម្រាប់ផ្សព្វផ្សាយបន្ទាន់

## សាលាឧទ្ធរណ៍ថៃត្រួសត្រាយផ្លូវសម្រាប់បណ្តឹងឆ្លងដែនសមូហភាពដំបូងបង្អស់ នៅតំបន់អាស៊ី  អាគ្នេយ៍ចំពោះការរំលោភបំពានសិទ្ធិមនុស្ស



តុលាការថៃផ្តល់ឋានៈបណ្តឹងសមូហភាពដល់ក្រុមកសិករកម្ពុជាដែលជាជនរងគ្រោះពីការបណ្តេញចេញពីលំនៅដ្ឋានដោយហិង្សាដែលជាការត្រួសត្រាយផ្លូវដើម្បីទទួលបានដំណោះស្រាយផ្លូវច្បាប់មុនគេនៅអាស៊ីអាគ្នេយ៍។

(ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០២០) - ភាគីដើមបណ្តឹងពលរដ្ឋកម្ពុជាដែលតំណាងឲ្យក្រុមគ្រួសារកសិកររងគ្រោះប្រមាណជាង ៧០០ គ្រួសារបានឈ្នះបណ្តឹងឧទ្ធរណ៍ ជាប្រវត្តិសាស្ត្រដែលអនុញ្ញាតឲ្យពួកគាត់បន្តឆ្ពោះទៅរកការដាក់ពាក្យបណ្តឹងសមូហភាពប្រឆាំងនឹងក្រុមហ៊ុនមីត្រផុល(Mitr Phol) ដែលជាក្រុមហ៊ុនផលិតស្ករសដ៏ធំបំផុតនៅតំបន់អាស៊ី។

បណ្តឹងសមូហភាពឆ្លងដែនរវាង អ្នកស្រីហួយ ម៉ៃ និងបុគ្គល ផ្សេងទៀតជាមួយនឹងក្រុមហ៊ុនមីត្រផុល គឺជាប្រភេទបណ្តឹងដំបូងគេនៅអាស៊ីអាគ្នេយ៍។ បណ្តឹងសមូហភាពនេះត្រូវបានដាក់ក្រោមច្បាប់របស់ប្រទេសថៃ ដែលអនុញ្ញាតឲ្យភាគីដើមបណ្តឹងជាជនបរទេសដាក់ពាក្យបណ្តឹងសមូហភាព ពីបទរំលោភបំពានដែលធ្វើឡើងដោយក្រុមហ៊ុនរបស់ថៃនៅក្រៅប្រទេស។

ពាក្យបណ្តឹងបានចោទប្រកាន់ក្រុមហ៊ុនមីត្រផុលពីបទពាក់ពន្ធ័ឲ្យមានការរុះរើលំនៅដ្ឋានរបស់ក្រុមគ្រួសារកសិករ ដោយបង្ខំដើម្បីយកដីរបស់ពួកគាត់មកធ្វើជាកសិឧស្សាហកម្មដំណាំអំពៅ នៅភាគពាយព្យនៃប្រទេសកម្ពុជា។ នៅចន្លោះឆ្នាំ ២០០៨ និង ២០០៩ ដីធ្លីរបស់គ្រួសារកសិករត្រូវបានរឹបអូស ហើយផលដំណាំរបស់ពួកគាត់ត្រូវបានបំផ្លាញ និងទន្ទ្រានយក ខណៈដែលផ្ទះសម្បែងរបស់ពួកគាត់ត្រូវបានវាយកម្ទេច និងដុតបំផ្លាញចោល។ អ្នកខ្លះត្រូវបានដាក់ពន្ធនាគារដោយសារតែការព្យាយាមការពារសិទ្ធិរបស់ខ្លួន។

សហគមន៍រងគ្រោះបានប្រយុទ្ធតស៊ូដើម្បីស្វែងរកយុត្តិធម៌ចាប់តាំងពីពេលនោះមក។ កាលពីឆ្នាំ២០១៥ គណៈកម្មការសិទ្ធិមនុស្សជាតិថៃបានរកឃើញថាក្រុមហ៊ុន មីត្រផុល ត្រូវទទួលខុសត្រូវចំពោះការទន្ទ្រានដីធ្លី និងបានអំពាវនាវឲ្យក្រុមហ៊ុន «ធ្វើការកែតម្រូវ និងដោះស្រាយផលប៉ះពាល់»។ រហូតដល់ពេលនេះ ក្រុមហ៊ុនមីត្រផុលបានបដិសេធយ៉ាងដាច់អហង្ការក្នុងការ ផ្តល់សំណងតាម រូបភាពណាមួយក៏ដោយដល់ក្រុមគ្រួសារកម្ពុជាចំពោះការបំផ្លិចបំផ្លាញដែលខ្លួនបានបង្កឡើងដល់ជីវិតរស់នៅរបស់ពួកគាត់ ។

យោងតាមសេចក្តីសម្រេចដែលទទួលស្គាល់ឋានៈនៃបណ្តឹងសមូហភាពរបស់តុលាការរដ្ឋប្បវេណីក្រុងបាងកកដែលបានចេញនៅថ្ងៃនេះបានអនុញ្ញាតឲ្យក្រុមគ្រួសាររងគ្រោះនាំយករឿងក្តីជាក្រុមដែលធានានូវសិទ្ធិទទួលបានយុត្តិធម៌ និងទប់ស្កាត់ដំណើរការដែលលំបាក និងចំណាយប្រាក់ ច្រើនក្នុងការនាំយកពាក្យបណ្តឹងរាប់រយដោយបុគ្គលនីមួយៗ។

*"ការឈ្នះក្តីថ្ងៃនេះគឺជាជំហានឆ្ពោះទៅមុខដ៏ធំមួយសម្រាប់ភាគីដើមបណ្តឹង និងប្រជាពលរដ្ឋទាំងអស់ដែលជាជនរងគ្រោះពីការបណ្តេញចេញ។ ឥឡូវនេះសំឡេងជនរងគ្រោះត្រូវបានគេស្តាប់។ សេចក្តីសម្រេចរបស់តុលាការបង្ហាញថាលទ្ធភាពទទួលបានយុត្តិធម៌អាចទៅរួច និងថាការតស៊ូអស់រយៈពេលមួយទសវត្សរបស់ពួកគាត់នឹងមិនឥតប្រយោជន៍នោះទេ"* នេះបើតាមប្រសាសន៍របស់លោក អឿង វុទ្ធី នាយកប្រតិបត្តិអង្គការ សមធម៌កម្ពុជា។

សម្រាប់ប្រទេសថៃ និងថ្នាក់តំបន់ សេចក្តីសម្រេចនេះផ្លាស់ប្តូរនូវទិដ្ឋភាពច្បាប់ដោយសារច្បាប់ស្តីពី បណ្តឹងសមូហភាព អាចត្រូវបានប្រើនៅក្នុងរឿងក្តីឆ្លងដែន និងដើម្បីការពារពលរដ្ឋងាយរងគ្រោះបំផុតនៅក្នុងតំបន់។

លោកស្រី Natalie Bugalski នាយកផ្នែកច្បាប់របស់អង្គការអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្នអន្តរជាតិ (Inclusive Development International) បានមានប្រសាសន៍ថា "សារៈសំខាន់នៃច្បាប់ជាអាទិភាព មិនអាចត្រូវបានមើលរំលងបានទេ" ។ "នេះគឺជារឿងក្តីរវាង David និង Goliath ដែលនឹងកំណត់ពីសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះពីការរំលោភបំពានរបស់ក្រុមហ៊ុនសាជីវកម្មនៅតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ផ្សេងទៀត" ។

វាក៏ជាការសាកល្បងដ៏សំខាន់មួយនៃគណនេយ្យភាពក្រុមហ៊ុនសាជីវកម្មផងដែរ។ មីត្រផុលគឺជាក្រុមហ៊ុនផ្គត់ផ្គង់ស្ករសដ៏ធំបំផុតនៅក្នុងតំបន់ និងមានអតិថិជនដែលជាម្ចាស់ម៉ាកយីហោល្បីធំៗមួយចំនួននៅលើពិភពលោក ដែលក្នុងនោះរួមមានក្រុមហ៊ុន Nestle, កូកា-កូឡា, Pepsi, Mars Wrigley និង Corbion ដែលជាអតិថិជនទាំងថ្មី និងចាស់រហូតដល់បច្ចុប្បន្ន។ ទោះបីជាក្រុមហ៊ុនកូកា-កូឡាបានចាត់វិធានការដំបូងដើម្បីស៊ើបអង្កេតលើបទចោទប្រកាន់ចំពោះក្រុមហ៊ុន មីត្រផុល ក៏ដោយ ក៏ប៉ុន្តែខ្លួនមិនបានប្រើអានុភាពរបស់ខ្លួនដើម្បីបង្ខំឲ្យក្រុមហ៊ុនផ្តល់សំណងដល់ជនរងគ្រោះនៅក្នុងប្រទេសកម្ពុជានោះទេ។ ផ្ទុយទៅវិញនៅឆ្នាំ ២០១៨ ក្រុមហ៊ុនកូកា-កូឡាបានជូនដំណឹងមកអង្គការអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្នអន្តរជាតិ (Inclusive Development International) ថាស្ករសដែលខ្លួនបានបញ្ជាទិញលែងមានប្រភព ពីក្រុមហ៊ុន មីត្រផុលទៀតហើយ។ ពួកគេមិនដែលរាយការណ៍ពីការបញ្ចប់ទំនាក់ទំនងផ្គត់ផ្គង់ជាសាធារណៈនោះទេ។

ក្រុមហ៊ុន មីត្រផុល (Mitr Pohl) ក៏ជាសមាជិករបស់អង្គភាពវិញ្ញាបនបត្រលើ "និរន្តរភាព" នៃឧស្សាហកម្មស្ករស មានឈ្មោះថា Bonsucro ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ស្ថាប័នទំនាក់ទំនងជាតិចក្រភពអង់គ្លេសសម្រាប់អង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD)(ស្ថាប័នរដ្ឋាភិបាលដែលឃ្លាំមើលប្រតិបត្តិការរបស់ក្រុមហ៊ុនអាជីវកម្មអង់គ្លេសនៅក្រៅប្រទេស) ចំពោះ

ការខកខានមិនបានដាក់ឲ្យក្រុមហ៊ុន មីត្រផុល (Mitr Phol) ទទួលខុសត្រូវចំពោះការរំលោភបំពានដែលខ្លួនបានប្រព្រឹត្តិលើសហគមន៍ទាំងនេះ។

សម្រាប់ក្រុមគ្រួសារដែល តំណាងនៅក្នុងពាក្យបណ្តឹងផ្លូវច្បាប់នេះ  បានប្រយុទ្ធតស៊ូអស់រយៈពេលមួយទសវត្សដើម្បីទាមទារយុត្តិធម៌។

*"នាងខ្ញុំ ជាតំណាងឲ្យប្រជាពលរដ្ឋក្នុងខេត្តឧត្តរមានជ័យ នាងខ្ញុំមានការត្រេកអរយ៉ាងខ្លាំងចំពោះលទ្ធផលនេះ ខ្ញុំសង្ឃឹមថា នឹងទទួលបានយុត្តិធម៌ក្នុងពេលខាងមុខ។ យើងខ្ញុំទាំងអស់គ្នានឹងតស៊ូបន្តទៀតរហូតដល់ទីបញ្ចប់"* នេះបើតាមប្រសាសន៍របស់អ្នកស្រី ហួយ ម៉ៃ ក្រោយពេលចេញដីកាសម្រេចកាលពីថ្ងៃសុក្រ។

*"ខ្ញុំសូមសារទរចំពោះតុលាការថៃដែលជួយគាំទ្រដល់ប្រជាពលរដ្ឋខ្មែរ នៅក្នុងខេត្តឧត្តរមានជ័យ ដោយសម្រេចថាបណ្តឹងរបស់យើងជា បណ្តឹងសមូហភាព។ ខ្ញុំសង្ឃឹមថា យើងខ្ញុំជាប្រជាពលរដ្ឋរងគ្រោះនឹងទទួលបានយុត្តិធម៌។ យោងតាមលទ្ធផលនេះ វាជាក្តីសង្ឃឹមថ្មីមួយទៀត សម្រាប់ការតស៊ូរបស់យើងទៅមុខទៀត"* នេះបើតាមប្រសាសន៍ លោក ស្មិន តិត តំណាងសហគមន៍រងគ្រោះ។

**ព័ត៌មានលំអិតសូមទាក់ទង៖**

- លោក អៀង វុទ្ធី នាយកប្រតិបត្តិអង្គការ សមធម៌កម្ពុជា

  **អ៊ីម៉ែល:** vuthy@equitablecambodia.org **ទូរសព្ទលេខ:** +៨៥៥ ១២ ៧៩១ ៧០០

- Craig Bradshaw, មន្ត្រីសម្របសម្រួលផ្នែកច្បាប់ប្រចាំតំបន់អាស៊ីអាគ្នេយ៍ អង្គការអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្នអន្តរជាតិ (Inclusive Development International)

  **អ៊ីម៉ែល:** craig@inclusivedevelopment.net

**ព័ត៌មានលំអិតបន្ថែមអំពីរឿងក្តីនេះអាចរកបាននៅទីនេះ**

**សម្រាប់វីដេអូរៀបរាប់ពីដំណើររឿងនៃការបណ្តេញចេញដោយបង្ខំ សូមចុចត្រង់នេះ។**